# កម្ពុជានឹងដាក់ឱ្យដំណើរការប្រព័ន្ធផ្លូវហោះហើរតាមផ្កាយរណបនៅចុងខែមិថុនា 2013ខាងមុខ



*ការថតរូបរួមគ្នានៅក្នុងកិច្ចប្រជុំគណៈកម្មការ (រូបថត សារ៉ាយ)*

**រាជធានីភ្នំពេញ ៖** ថ្លែងប្រាប់អ្នកសារព័ត៌មាន បន្ទាប់ពីកិច្ចប្រជុំគណៈកម្មការសម្របសម្រួលផែនការអភិវឌ្ឍន៍គម្រោងនាំផ្លូវអាកាសដោយប្រព័ន្ធផ្កាយរណប ដែលរៀបចំធ្វើនៅថ្ងៃទី១៨ ធ្នូ ឆ្នាំ២០១២ នៅសណ្ឋាគារភ្នំពេញ លោកសយ សុខាន់ អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានប្រសាសន៍ថា ប្រទេសកម្ពុជានឹងដាក់ឱ្យដំណើរការប្រព័ន្ធផ្លូវហោះហើរតាមផ្កាយរណបនៅក្នុងអាកាសយាន្តដ្ឋានអន្តរជាតិភ្នំពេញនៅចុងខែមិថុនា ឆ្នាំ២០១៣ខាងមុខនេះ ។

លោកសយ សុខាន់ បន្តថា គម្រោងមួយនេះត្រូវបានអង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICO) ចេញសេចក្ដីសម្រេចមួយកាលពីឆ្នាំ២០០៧ ដើម្បីឱ្យប្រទេសជាសមាជិករៀបចំអនុវត្តនូវគម្រោងការនេះ ។ ដោយផ្អែកលើស្ថានភាពនេះ ប្រទេសជប៉ុនតាមរយៈអង្គការ JICA បានធ្វើការរៀបចំផែនការមេឱ្យបណ្ដាប្រទេសនៅក្នុងតំបន់អាស៊ានចំនួន៣មាន កម្ពុជា វៀតណាម និងឡាវ ហើយផែនការមេនេះបានបញ្ចប់នៅឆ្នាំ២០០៩ ។ លោកបញ្ជាក់ថា រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាបានរៀបចំរួចរាល់ហើយនូវប្រព័ន្ធចុះចតដោយផ្កាយរណបនេះនៅក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ។ ប្រព័ន្ធមួយនេះនឹងដាក់ឱ្យដំណើរការនៅក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅពាក់កណ្ដាលឆ្នាំ២០១៣ និងនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបនៅចុងឆ្នាំ២០១៣ ។ ចំណែកអាកាសយានដ្ឋានក្នុងខេត្តព្រះសីហនុ គ្រោងនឹងដាក់ឱ្យដំណើរការនូវប្រព័ន្ធមួយនេះដែរនៅក្នុងអំឡុងឆ្នាំ២០១៤ ។

លោកសយ សុខាន់ បានអះអាងបន្ថែមថា ប្រព័ន្ធមួយនេះគឺមានសារសំខាន់សម្រាប់ក្រុមហ៊ុនអាកាសចរ និងការប្រតិបត្តិការនៅក្នុងអាកាសយានដ្ឋាន និងប្រតិបត្តិករតាមផ្លូវអាកាស ហើយវាក៏អាចធ្វើឱ្យយើងមានផលចំណេញច្រើនទាក់ទងទៅនឹងពេលវេលាហោះហើរ និងការហោះហើរមានលក្ខណៈត្រង់ ហើយមានសុវត្ថិភាព ។ លោកបញ្ជាក់ថា គម្រោងមួយនេះជាការឆ្លើយតបមួយថ្មីទៀតចំពោះរាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍផ្លូវហោះហើរឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃភ្ញៀវទេសចរដែលមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ ដោយយោងទៅលើសន្ទុះនៃភ្ញៀវទេសចរដែលមានការកើនឡើងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏មានគម្រោងពង្រីកអាកាសយានដ្ឋានបន្ថែមទៀត ដើម្បីងាយស្រួលសម្រាប់ការដឹកជញ្ជូនភ្ញៀវតាមផ្លូវអាកាសនេះ សម្រួលដល់ទាំងអ្នកទេសចរ ធុរជន និងសម្រាប់សង្គមយើងផងដែរ ។

លោកអនុរដ្ឋលេខាធិការបន្ថែមថា តាមរយៈគម្រោងពង្រីកអាកាសយានដ្ឋានបន្ថែមនៅក្នុងព្រះរាជាណាចក្រកម្ពុជានេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនឹងរៀបចំគម្រោងដាក់ជូនរដ្ឋាភិបាលពិនិត្យ ដើម្បីសិក្សាទៅលើសក្ដានុពលទេសចរណ៍នៅតាមខេត្តមួយចំនួន ៕

***សារ៉ាយ***